## សុន្ទរកថា




សិស្សថ្លែងសុន្ទរកថាម្នាក់ 2 នាទី អំពីបញ្ហាសង្គមនានាដែលពួកគេបានជ្រើសរើស នៅអំឡុងសប្តាហ៍ទី 4 នៃវគ្គសិក្សាទីមួយ។ មានប្រធានបទសរុបចំនួន 13 ហើយ ទោះបីជាពួកគេមានអារម្មណ៍ភិតភ័យនៅអំឡុងពេលថ្លែងសុន្ទរកថាដំបូងក្តី ក៏ពួកគេបានបញ្ចប់បទបង្ហាញទាំងអស់ប្រកបដោយការទទួលខុសត្រូវ។ ពួកគេបានពន្យល់អំពីមូលហេតុរបស់ពួកគេក្នុងការជ្រើសរើសបញ្ហាសង្គមនោះ ដោយផ្តល់ទស្សនៈយល់ឃើញអំពីស្ថានភាពបច្ចុប្បន្ន និងផ្តល់ដំណោះស្រាយដែលអាចធ្វើបាន។

## អប់រំកាយ



ថ្នាក់អប់រំកាយ (PE) ប្រព្រឹត្តទៅនៅមជ្ឈមណ្ឌលកីឡា YMCA ដែលអាចដើរដល់ត្រឹម 5 នាទីប៉ុណ្ណោះពីសាលារៀន នៅរៀងរាល់រសៀលថ្ងៃសុក្រ។ ឆមាសនេះ សិស្សនឹងហាត់រៀនកីឡាបាល់បោះ ដោយមានការដាក់ពិន្ទុសម្រាប់ការបញ្ជាគ្រប់គ្រងបាល់ ការបណ្តើរបាល់ ការបោះបាល់បញ្ជូន និងការបោះបាល់បញ្ចូលទី។ ដោយសារតែយើងមានសិស្សដែលពុំធ្លាប់បានលេងប៉ះបាល់បោះពីមុនមកសោះ និងអ្នកផ្សេងទៀតដែលរីករាយនឹងការប្រកួតកីឡានេះស្រេចហើយ យើងបានបែងចែកពួកគេទៅជាបីក្រុម។ អ្នកទើបចូលរៀនបានចាប់គូគ្នាដើម្បីហាត់ត្រេះបណ្តើរបាល់ និងបោះបញ្ជូនបាល់។ នៅពេលនេះ សូម្បីតែអ្នកដែលមិនធ្លាប់លេងបាល់បោះពីមុនមក ក៏ស្រឡាញ់ពេញចិត្ត និងចូលរួមលេងដោយក្តីរីករាយដែរ!

**កីឡាជាច្រើនទៀត...**
កីឡាវាយសី បាល់ទះ និងបាល់បោះណិតបល (netball) ត្រូវបានកំណត់ពេលលេងសម្រាប់ឆមាសបន្ទាប់

## ជីវវិទ្យា






ថ្នាក់ជីវវិទ្យាគឺមានលក្ខណៈពិសេសខុសពីថ្នាក់រៀនធម្មតា។ យើងបានធ្វើដំណើរទៅកាន់ឧទ្យាន Myers Park ដែលជាឧទ្យានដ៏ធំមួយនៅខាងក្រោយបរិវេណសាលា សម្រាប់ការធ្វើពិសោធន៍អនុវត្ត។ សិស្សបានអង្កេតមើលរុក្ខជាតិដែលពួកបានចាប់អារម្មណ៍ បានប្រើប្រាស់កម្មវិធីសម្រាប់ទទួលបានព័ត៌មាន និងបានចងក្រងឯកសារលទ្ធផលដែលពួកគេរកឃើញ រួមជាមួយកំណត់ត្រានិងរូបភាពគំនូរ។ ពីរសប្តាហ៍ក្រោយមក ពួកគេនឹងធ្វើបទបង្ហាញអំពីរុក្ខជាតិដែលពួកគេបានសិក្សាស្វែងយល់។
ដើម្បីសិក្សាជីវវិទ្យា សិស្សចាំបាច់ត្រូវចេះពាក្យជាភាសាអង់គ្លេស។ Ve គឺជាសិស្សដ៏ឆ្នើមម្នាក់នៅក្នុងថ្នាក់កម្មវិធីសិក្សាលក្ខណៈបុគ្គល (PLP) របស់យើង ហើយគាត់នឹងពន្យល់គ្រប់ពាក្យទាំងអស់ដែលគាត់បានសិក្សារៀនសូត្រដោយគូររូបភាពបង្ហាញជូនដល់អ្នកគ្រប់គ្នា។

# គណិតវិទ្យា







ក្នុងថ្នាក់គណិតវិទ្យា សិស្សចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផ្សេងៗដូចជា ល្បែងក្តារបន្ទះ លំហាត់ខ្លីៗ និងលំហាត់ក្នុងសៀវភៅសិក្សាគោល។ សិស្សបានសិក្សាអំពីប្រធានបទដូចជា រូបរាងបន្ទាត់ និងសមីការ ហើយពេលនេះកំពុងត្រៀមខ្លួនសិក្សាមុខវិជ្ជា ស្ថិតិរហូតដល់ថ្នាក់ទីប្រាំមួយ។ ពួកគេភាគច្រើនគិតថាថ្នាក់រៀននេះមានភាពរីករាយមិនគួរឱ្យជឿ ហើយមុខវិជ្ជាស្ថិតិគឺជាប្រធានបទថ្មីមួយសម្រាប់ពួកគេ!




**នៅពេលបន្ទាប់...**
ការទៅទស្សនាសារមន្ទីរ Auckland Museum និងការធ្វើដំណើរជិះនាវាកម្សាន្ត



# វិញ្ញាបនបត្រសិក្សាថ្នាក់មូលដ្ឋាន







សិស្សក្នុងកម្មវិធី PLP បានចូលរួមថ្នាក់សិក្សានៅក្នុងកម្មវិធីវិញ្ញាបនបត្រសិក្សាថ្នាក់មូលដ្ឋាននៅពេលនេះ ដោយផ្តោតទៅលើកម្មវិធី EAP (ភាសាអង់គ្លេសសម្រាប់គោលដៅសិក្សា)។ សិស្សកម្មវិធី PLP ត្រូវបានបែងចែកទៅកាន់ថ្នាក់ចំនួនប្រាំពីរផ្សេងៗគ្នា ដោយចូលរួមនៅក្នុងសកម្មភាពផ្សេងៗដូចជា ការធ្វើតេស្តសាកល្បង និងវគ្គសិក្សាដាក់ពិន្ទុវាយតម្លៃដោយមិត្តរួមថ្នាក់។ ពួកគេបានរួមបញ្ចូលយ៉ាងរលូនទៅក្នុងថ្នាក់រៀន ដែលគាំទ្រដោយសិស្សថ្នាក់មូលដ្ឋានជំនាន់មុន។ នៅក្នុងរយៈពេលពីរបីថ្ងៃបន្ទាប់ សិស្សកម្មវិធី PLP នឹងបន្តចូលរួមក្នុងថ្នាក់សិក្សាមូលដ្ឋានដែលមានមុខវិជ្ជាសិក្សាខុសៗគ្នា។ បទពិសោធន៍នេះនឹងផ្តល់ឱ្យសិស្សកម្មវិធី PLP នូវការប្រឡូកខ្លួនទៅក្នុងកាលវិភាគនិងមជ្ឈដ្ឋានសិក្សាដែលបានរៀបចំតាមរចនាសម្ព័ន្ធ ដោយលើកកម្ពស់ទំនុកចិត្តនៅក្នុងការចូលរួមរបស់ពួកគេ។

# ម៉ោងពិសាអាហារថ្ងៃ


Library




Cafeteria



អំឡុងពេលអាហារថ្ងៃត្រង់ សិស្សមានជម្រើសផ្សេងៗ៖ សិស្សខ្លះយកអាហារថ្ងៃត្រង់ដែលបានវេចខ្ចប់ផ្ទាល់ខ្លួនរបស់ពួកគេមកពីកន្លែងដែលពួកគេស្នាក់នៅ ចំណែកសិស្សខ្លះទៀតអាចរីករាយជាមួយនឹងការផ្តល់ជូនពិសេសក្នុងតម្លៃសមរម្យពីអាហារដ្ឋាននៅក្នុងបរិវេណសាលា ដែលរួមមានអាហារដូចជា ស៊ូស៊ី ដុនប៊ូរិ និងសាំងវិចជាដើម។ ផ្ទះបាយសម្រាប់សិស្សគឺនៅជិតបណ្ណាល័យ ដែលសិស្សអាចទស្សនាឬមើលខ្លឹមសារផ្សព្វផ្សាយ ធ្វើកិច្ចការសាលា ឬខ្ចីសៀវភៅតាមពួកគេចង់បាន។ ពិតមែនហើយ សិស្សក៏អាចទៅកាន់បណ្ណាល័យសាកលវិទ្យាល័យ និងបណ្ណាល័យសាធារណៈនានានៅក្នុងទីក្រុងបានផងដែរ។ បណ្ណាល័យ Auckland Central Library ដែលស្ថិតនៅជិតបរិវេណសាលា គឺជាទីកន្លែងសម្រាប់សិស្សរបស់យើង។